Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date: 22 6 99 ID no: 010701 Team: Sokhym + Nean
Latitude: N 13 56 53 05 Longitude: E 103 02 59 02
File # 062208 A Time 3H : 35 Location: ________

Site Name: Banteay [Kh]: បន្ទាយ khet: ~~Kampong Chhnang~~ Banteay Meanchey
srok: Thmar Pouk khum: Thmar Pouk phum: Kak Sin

| 1. PRISON | | 2. Burial site (circled) | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | ____ | Pit | ✓ | Wat | ____ |
| Previous Prison | ____ | Kiln | ____ | Stupa | ____ |
| Purpose Built | ____ | Rice paddy | ____ | Brick/tile | ____ |
| School | ____ | River/lake | ____ | Wooden | ____ |
| Wat | ____ | Well | ____ | Other | ____ |
| House | ____ | Execution | ✓ | | |
| Other | ____ | Other | ____ | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
In the north about 700m from the district Office along the road number 69A about 10m in the West. There is a Krasaing tree about 4m away from the site.

WITNESS: Name Ek Sanvath Age 47. Sex M Address
phum Andaung Khlong khum Kumrou srok Thmar Pouk
khet Banteay Meanchey Identity ________

Estmated number of victim Over 400 Pits 4 Other ________
[according to the witness ✓ Report ____ Other ________]
Photos: ________ Roll Number: ________ Shots number ________
Documents: ________

Interview: The witness said One truck is not enough to put the borns of Victim in.

Comments: ________

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date: 22.6.99 ID no: 010702 Team: Sokhym + Neau
Latitude: N 13 55 47 23 Longitude: E 103 02 45 25
File # 062208 B Time 4H:00 Location: ____

Site Name: Andaung Sep Pheng [Kh]: អណ្ដូងសិបភេង khet: Banteay Meanchey
srok: Thmar Puork khum: Kumrou phum: Ekkakpheap

| 1. PRISON | | 2. Burial site (circled) | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | ____ | Pit | ✓ | Wat | ____ |
| Previous Prison | ____ | Kiln | ____ | Stupa | ____ |
| Purpose Built | ____ | Rice paddy | ____ | Brick/tile | ____ |
| School | ____ | River/lake | ____ | Wooden | ____ |
| Wat | ____ | Well | ____ | Other | ____ |
| House | ____ | Execution | ✓ | | ____ |
| Other | ____ | Other | ____ | | ____ |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
About 50m in the west of Road No 69A. It is in the North of CCP headquarter.

WITNESS: Name Hap Svang Age 69 Sex M Address
phum Ekakpheap khum Kumrou srok Thmar Puork
khet Banteay Meanchey Identity ____

Estmated number of victim Over 300 Pits 1 Other ____
[according to the witness ✓ Report ____ Other ____]
Photos: ____ Roll Number: ____ Shots number ____
Documents: ____

Interview: The witness said the pit is 9m x 4m and 10m high. But it had, now gradually filled by the soil

Comments: ____

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 22. 6. 99 ID no: 010703 Team : Sokhym + Nean
Latitude : N 14 00 44 51 Longitude : E 103 04 05 59
File # 062209A Time 4:53 Location: ______

Site Name : Trapaang Suon [Kh] : ត្រពាំងសួន khet : Banteay Meanchey
srok : Thmar Puork khum : Banteay Chhmar phum : Thmar Dekkes

| 1. PRISON | | 2. Burial site (circled) | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | ✓ | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | | River/lake | | Wooden | |
| Wat | | Well | | Other | |
| House | | Execution | ✓ | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
In the North of Chamrak Dekkes and about 250m in the west of road number 69A.

WITNESS: Name Ky Keav Age 53 Sex M Address
phum Ekakpheap khum Kumrou srok Thmar puork
khet Banteay Meanchey Identity ______

Estmated number of victim ______ Pits 2 Other ______
[according to the witness ____ Report ____ Other ______]
Photos : ______ Roll Number : ______ Shots number ______
Documents: ______

Interview : Ky Keav is a royal army in the rang of Captain. He is also a commander in the military engineering unit of F7 (Devision #7). He can not estimate the number of Victim at this site.

Comments: ______

# របាយការណ៍ស្តីពីការចុះស្រាវជ្រាវទីតាំងគុក រណ្តៅសាកសព និង បទសំភាសន៍ជាមួយជនរងគ្រោះ

### ថ្ងៃទី ២១-៦-១៩៩៩ ដល់ ២៥-៦-១៩៩៩

នៅរសៀលថ្ងៃទី ២១-៦-១៩៩៩ ក្រុមរៀបចំផែនទីមួយក្រុម រួមមាន លោក **ស៊ិន ឃ៊ិន** ជាអ្នកទំនាក់ទំនងបណ្តាអជ្ញាធស្រុក និងតាមបណ្តាភូមិឃុំ ហើយក៏ជាអ្នកសំភាសន៏សាក្សីដែរ ទីពីរ លោក **អ៊ុច សំអឿន** ជាអ្នកកាន់ម៉ាស៊ីន GPS សំរាប់កណត់ទីតាំងរណ្តៅសាកសព, កន្លែងតំកល់អដ្ឋិធាតុ និងគុក ទីបី លោក **វ៉ាន់ថាន់ ពៅដារ៉ា** ជាអ្នកបំពេញពតិមានអំពីទីតាំងនិមួយៗ [ Site form] និងជាអ្នកជួយសំភាសន៏សាក្សី ទីបួន លោក **យិន នាន** ជាអ្នកគូរប្លង់ផែនទីស្តីពីរណ្តៅ និងគុក ទីប្រាំ គឺនាងខ្ញុំ **អែម សុឃីម** ជាអ្នកកត់ត្រា និងអ្នកសរសេរ របាយការណ៏ ។

ក្រុមរបស់យើងបានធ្វើដំណើរតាមផ្លូវអាកាសពីភ្នំពេញ ទៅបាត់ដំបង ។ ប៉ុន្តែពីបាត់ដំបងទៅខេត្តបន្ទាយមានជ័យ គឺត្រូវធ្វើដំណើរដោយរថយន្ត ។

នៅម៉ោង ៣:៣០នាទី ក្រុមយើងបានចុះពីយន្តហោះនៅខេត្តបាត់ដំបង ហើយក៏បន្តដំណើរឆ្ពោះទៅកាន់ខេត្តបន្ទាយមានជ័យ ដែលមានចំងាយប្រមាណ ៧០ គ.ម ។ នៅម៉ោង ៥:៣០ នាទី ក្រុមផែនទីរបស់យើង បានទៅដល់ទីរួមខេត្តបន្ទាយមានជ័យ ។

ថ្ងៃបន្ទាប់ គឺថ្ងៃ ២២-៦-១៩៩៩ ព្រឹក វេលាម៉ោង ៨:៣០នាទី ក្រុមរបស់យើងបានទៅសាលាខេត្តបន្ទាយមានជ័យ ដើម្បីទៅទំនាក់ទំនងអាជ្ញាធរខេត្ត សាកសួរពតិមានស្តីពីទីតាំងភូមិសាស្រ្ត ដែលត្រូវទៅ ប៉ុន្តែគួរអោយសោកស្តាយ ក្រុមរបស់យើងពុំបានជួបលោកអភិបាលខេត្តទេ ព្រោះលោកអភិបាលខេត្តជាប់រវល់ទៅទទួលគណៈប្រតិភូរបស់ថៃនៅឯប្រាសាទបន្ទាយឆ្មារ បាត់ទៅហើយ តាំងពីថ្ងៃទី ២១-៦-១៩៩៩ ម្ល៉េះ ។ ហើយក៏ជាសំណាងល្អរបស់ក្រុមយើងដែរ គឺបានជួបលោក **ឡៀប ឈួន** ជានាយរងខុទ្ទកាល័យខេត្ត ដែលលោកបានផ្តល់ពតិមានអោយយើងដឹងថា ស្រុកបន្ទាយអំពិលសព្វថ្ងៃ មិនមែនស្ថិតនៅក្នុងចំណុះខេត្តបន្ទាយមានជ័យទៀតទេ ក្រោយការបោះឆ្នោត ១៩៩៨ ស្រុកនេះត្រូវកាត់ផ្តាច់ទៅឱ្យ ខេត្តឧត្តរមានជ័យបាត់ទៅហើយ បើពួកយើងចង់ទៅ ទាល់តែទៅទំនាក់ទំនងចៅហ្វាយខេត្តឧត្តរមានជ័យជាមុនសិន ឯលក្ខណៈភូមិសាស្រ្តវិញ មានការលំបាកខ្លាំងណាស់គឺដោយផ្លូវមានចំងាយប្រមាណជា ៧០គ.ម ពីទីរួមខេត្តបន្ទាយ

មានជ័យ ទាល់តែចំណាយពេលមួយថ្ងៃក្នុងការធ្វើដំណើរ ទើបអាចធ្វើការបាន រីឯទីតាំងស្រុកស្ថិតនៅសំរោង អាចធ្វើ ដំណើរតាមផ្លូវជាតិ លេខ ៦ ។

លោកក៏បានប្រាប់ពីទីតាំងផ្លូវទៅកាន់ស្រុកថ្មពួកថា មានចំងាយផ្លូវមានតែ ៤៣ គ.ម ទេ តែប្រើរយៈពេលនៃការធ្វើដំណើររហូតដល់ជិត ៤ ម៉ោង ព្រោះបណ្តាលមកពីផ្លូវលំបាក ទើបប្រើរយៈពេលយូរយ៉ាងនេះ ឯសន្តិសុខតាមផ្លូវក៏មានលក្ខណៈល្អដែរតាំងពីរាជរដ្ឋាភិបាលមានវិធានការណ៍ដកហូតអាវុធមក ។ បន្ទាប់ពីសាកសួរពីលោកនាយកខុទ្ទកាល័យរួចមក ក្រុមរបស់យើងក៏បានសំរេចបន្តរដំណើរទៅស្រុកថ្មពួក តាមផ្លូវ ៦៩ អា ឆ្ពោះទៅថ្មពួក ដែលឆ្លងកាត់ ស្រុកសេរីសោភណ័ និងស្រុកស្វាយចេក តាមបណ្តោយផ្លូវដីសែនលំបាក ដែលមានទាហ៊ានរាយនៅតាមផ្លូវជាក្រុម១ៗរហូតដល់ទីរួមស្រុក ។

នៅម៉ោង ១២:៣០នាទី ថ្ងៃដដែល ក្រុមរបស់យើងបានមកដល់ស្រុកថ្មពួក ហើយបានទៅទំនាក់ទំនងផ្នែករដ្ឋបាល ក៏បានទៅជួបលោក **ហ៊ាន ណារុន** ហៅ **ឆាត** ជាអភិបាលរងស្រុកថ្មពួក លោកមានប្រសាសន៏ថា លោកបានដឹងដំណឹងពីក្រុមស្រាវជ្រាវយើងជាមុនទៅហើយ ដោយនាយរងខុទ្ទកាល័យខេត្តជាអ្នកប្រាប់តាមរយៈ Icom កាលពីព្រឹក គឺសូមអោយជួយយើងខ្ញុំបង្ករលក្ខណៈងាយស្រួលដល់ក្រុមរបស់យើងផង ។ លោក **ហ៊ាន ណារុន** ក៏បានប្រាប់ពីពតិមានខ្លះៗ ពីស្ថានភាពភូមិសាស្ត្រ និងសន្តិសុខក្នុងស្រុកថា ស្រុកថ្មពួកនេះមាន ៦ឃុំ គឺ ឃុំថ្មពួកមាន ៧ភូមិ ឃុំភូមិថ្មីមាន ៨ភូមិ ឃុំបន្ទាយឆ្មារមាន ១១ភូមិ ឃុំរការមៀតមាន ២០ភូមិ ឃុំគំរូមាន ៦ភូមិ ឃុំកបិនមាន ៨ភូមិ សរុបទាំងអស់មានចំនួន ៦០ ភូមិ ចំនួនប្រជាជន ៧៩៨៧៦ នាក់ ស្រី ២៦៧៤៩ នាក់ ត្រូវជា ១០៦១៥ គ្រួសារ, ប្រជាជនស្ទើរតែ ៩៩% ធ្វើកសិកម្ម ជីវភាពប្រជាជននៅស្រុកនេះមានការយ៉ាប់យឺនជាងស្រុកដទៃទៀតក្នុងខេត្តបន្ទាយមានជ័យនេះ ព្រោះប្រជាជនប្រកបរបរធ្វើស្រែចំការតែមួយមុខ ឯត្រីសាច់ក្នុងស្រុកនេះពុំសូវមានទេ ។

ឯលក្ខណៈភូមិសាស្ត្រស្រុកនេះស្ថិតនៅភាគឥសាន្តឆៀងខាងជើង ពីទីរួមខេត្តបន្ទាយមានជ័យ ចំងាយផ្លូវ ៤៣ គ.ម ព្រំប្រទល់ខាងលិចជាប់ប្រទេសថៃ ខាងកើតជាប់ស្រុកភ្នំស្រុក ខាងត្បូងជាប់ស្រុកស្វាចេក ខាងជើងជាប់ស្រុកបន្ទាយអំពិល ។

ចំពោះសភាពការណ៏ផ្នែកសន្តិសុខនៅស្រុកនេះកាលពីឆ្នាំ ១៩៨៩ ត្រូវពួកចលនាតស៊ូរំដោះបាន ដូច្នេះរាល់រចនាសម្ព័ន្ធទាំងអស់ ត្រូវចាត់តាំងឡើងដោយពួកចលនារំដោះ ឯចលនារំដោះនោះ គឺពួកគណៈបក្សហ៊្វុនស៊ិនប៉ិច(ទ័ពប៉ារ៉ា) ។រហូតដល់ក្រោយបោះឆ្នោត១៩៩៣ ស្រុកនេះត្រូវទទួលស្គាល់ដោយគណៈបក្ស សឺនសាន ក្រោយមកមានគណៈបក្សហ៊្វុនស៊ិនប៉ិច ។ ឯភាគីគណៈបក្សប្រជាជន មិនទាន់មានសមាសភាពទេ ។ ទំរង់រដ្ឋ

បាលក្នុងស្រុក ធ្វើតាមបែបយោធានិយម ព្រោះយោធាជាអ្នកគ្រប់គ្រង ទោះបីមានអាជ្ញាធរស្រុកជារបៀបស៊ីវិលមែន តែអ្វី១ទាំងអស់ដែលត្រូវអនុវត្តន៏ ត្រូវសួរយោបល់ពីយោធាសិន ទើបហ៊ានសំរេច ។

នៅក្នុងឆ្នាំ១៩៩៧ ថ្នាក់លើបានកំណត់អោយលោក **ណារុន** ចូលមកក្តាប់ស្រុកនេះ តែសភាពការណ៏មិនអនុគ្រោះ លោកក៏ត្រូវទៅបន្តការសិក្សានៅសាលាភូមិន្ទរដ្ឋបាល រយៈពេលមួយឆ្នាំ (ឆ្នាំ១៩៩៨-១៩៩៩) លោកក៏បានបន្ថែមថា សភាពការណ៏ពីពេលមុន និងឥឡូវ ខុសគ្នាឆ្ងាយណាស់ ដោយស្ថានភាពនយោបាយល្អ សង្គ្រាមត្រូវបញ្ចប់ កំលាំងឆ្វេង និងស្តាំ ត្រូវជំរុះអស់ ហើយយោធាកំពុងស្វែងយល់ និងសិក្សាអំពីច្បាប់ និងអ្វីដែលជាអំណាចរបស់អាជ្ញាធរដែនដី ។ ពួកយោធាមិនលូកដៃដូចកាលមុនទៀតទេ ដោយសារស្រុកមានសន្តិភាពហើយ ទើបយោធាលែងរវល់ ហើយខិតខំការងារអភិវឌ្ឍន៏តាមបច្ចេកទេសបែបថ្មី ដោយស្គាល់តួនាទី និងការងារ របស់គេរៀង១ខ្លួន ។

លោកក៏បានរៀបរាប់ពីជីវិតរបស់លោកកាលពីសម័យប៉ុលពតថា រូបលោកមានស្រុកកំណើត នៅភូមិថ្មពួក ស្រុកថ្មពួក ខេត្តបាត់ដំបង ហើយសិក្សានៅស្រុកសេរីសោភ័ណ ។ ឯឪពុក ជានាយទាហ៊ានម្នាក់ ។ ក្រោយរដ្ឋប្រហារទំលាក់សីហនុ លោកក៏បន្តទៅសិក្សានៅភ្នំពេញ ។ ក្រោយជ័យជំនះរបស់ខ្មែរក្រហម ក្រុមគ្រួសាររបស់លោកបានជន្លៀសចេញពីភ្នំពេញ មកនៅស្រុកបាកាន ខេត្តពោធិសាត់ ។ លោកមានបងប្អូន ៦នាក់ និងម្តាយត្រូវស្លាប់ដោយដាច់ពោះក្នុងឆ្នាំ ១៩៧៦ ។ ឯឪពុករបស់លោកត្រូវអង្គការ ១៧ មេសា ហៅទៅរៀនសូត្រ ព្រោះពួកវាដឹងថាជាទាហ៊ាន ក្រោយមកទើបដឹងថាគាត់ស្លាប់ហើយ ។ ពេលនោះក្នុងចុងឆ្នាំ ១៩៧៦ ពួកប៉ុលពតបានប្រាប់ថា បើបងប្អូនណារស់នៅក្នុងភូមិភាគពាយព្យ អង្គការអនុញ្ញាតអោយទៅរស់នៅទីនោះវិញ ។ ព្ញដូច្នោះ រូបលោកក៏ធ្វើដំណើរតាមកប៉ាល់ពីវត្តចំពុះក្អែក ស្រុកបាកាន បន្តទៅស្រុកស្វាយដូនកែវ ហើយក៏សំរាកនៅទីនោះមួយយប់ ស្អែកឡើងពួកខ្មែរក្រហមយករទេះទៅដឹកបន្តដោយប្រាប់ថា "ទៅលើ" គឺទៅភូមិដំណាក់ពង្រ ឃុំឫស្សីក្រាំង ស្រុកមោងឫស្សី ហើយស្រុកនេះត្រូវបានកាត់បញ្ចូលក្នុងតំបន់២ ។ ពេលមកដល់ស្រុកនេះ រូបលោកត្រូវពួកខ្មែរក្រហមបង្ហាញដំបូកមួយអោយកាប់ឆ្កាព្រៃ ដើម្បីធ្វើកន្លែងសំរាក ពេលនោះរូបលោកទើបតែអាយុ ១៦ឆ្នាំ ហើយអ្វី១ក៏ពុំចេះធ្វើដែរ តែដោយកាលនៅជាយុវ៏នសម័យលន់ណុល មានការបង្រៀនអោយចេះបោះតង់ លោកក៏យកកៅស៊ូមកបោះតង់ធ្វើកន្លែងសំរាក ។ បន្ទាប់មកពួកខ្មែរក្រហមបង្ខំអោយរូបលោកចូលកងចល័តតំបន់ ដោយអោយធ្វើការជាទំងន់ ឯជីវភាពវិញពុំគ្រប់គ្រាន់ទេ គឺវេទនាណាស់ មួយកំប៉ុងអង្ករសំរាប់ គ្នា ២០ នាក់ ឬ ៥០ នាក់ ។ ដោយសេចក្តីស្រេកឃ្លានពេក លោកក៏ដាច់ចិត្តដោះខោអាវដែលកំពុងស្លៀកនិងខ្លួន ដូរយកកន្ទក់មកលីងហូប ។ ពេលបត់ជើងធំម្តង១ពិបាកណាស់ ទាល់តែយកដៃជួយរុញបន្ថែមទើបចេញ ឯលាមកវិញ ដូចលាមកជ្រូក ឯដាន គឺដានមនុស្ស ។

នៅទីបញ្ចប់លោកបានបញ្ជាក់អំពីភស្តុតាងនានារបស់ប៉ុលពត គឺលោកពុំសូវដឹងទេ ព្រោះពេលលោកត្រឡប់មកនៅស្រុកនេះគឺភស្តុតាងត្រូវរលត់រលាយអស់ហើយ ហើយអ្វីដែលលោកនិយាយជាការពិត គឺរូបលោកមិនបង្កាច់បង្ខូចខ្មែរក្រហមទេ ។

បន្ទាប់ពីជួបលោក **ហ៊ាន ណារុន** រួចមកនៅម៉ោង ២:៣០ នាទី រសៀល ក្រុមរបស់យើងបានទៅជួបលោក **ឯក សខាត** អាយុ ៤៧ ឆ្នាំ មានស្រុកកំណើតនៅ ភូមិអណ្តូងថ្លុង ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបាត់ដំបង ។ ទីលំនៅសព្វថ្ងៃរបស់លោក **ឯក សខាត** នៅភូមិអណ្តូងថ្លុង ឃុំថ្មពួក ខេត្តបន្ទាយមានជ័យ មានតួនាទីជាប្រធានមន្ទីរស្រុកថ្មពួកនេះ ។ លោកបានរៀបរាប់ថា នៅសម័យ ៣ ឆ្នាំ ៨ ខែ ស្ថានភាពភូមិសាស្ត្រនៅស្រុកនេះ គឺស្ថិតក្នុងតំបន់ ៥ ភូមិភាគពាយព្យ មានទីតាំងសាលាស្រុកនៅក្នុងភូមិកបិន ឃុំថ្មពួក ស្រុកថ្មពួក ឯមន្ទីរសន្តិសុខនៅកន្លែង គណៈបក្សប្រជាជនសព្វថ្ងៃនេះ ។ គណៈស្រុកខ្មែរក្រហមនៅតំបន់នេះឈ្មោះ **ឆាត** ក្រោយមក **ឆាត** ត្រូវពួកនិរតី យកទៅសំលាប់ ដោយចោទថាខ្មាំង ។ រូបលោកបានរស់នៅក្នុងភូមិ កំណើតរបស់លោកដដែល មានឋានៈជាកសិករធម្មតា ត្រូវជាប់ចោទពីពួកប៉ុលពតថា ជានិន្នាការនិស្សិត ។ តាមពិតរូបលោកគ្រាន់តែជាអ្នកចេះដឹងបន្តិចបន្តួចប៉ុណ្ណោះ ។ ចំពោះការជាប់ចោទនេះ ត្រូវពួកខ្មែរក្រហមតាមដានរហូតដល់ធ្វើតេស្តសាកល្បងមើលទៀត ។ ឯឪពុក ម្តាយរបស់លោកជាអ្នកមានធនកណ្តាល ។ ឪពុកលោកគឺជាគ្រូប្រដៅខាងសាសនាព្រះពុទ្ធនៅតំបន់នេះ ហើយក៏ត្រូវជាប់ចោទពីពួកថាជា "ទាហានព្រះ" តាមពិតគាត់ជាអាចារ្យធម្មតាទេ មិនមែនជា " ទាហ៊ានព្រះ " ដូចពួកវាចោទប្រកាន់នោះទេ ។ ចំពោះការសំលាប់ប្រជាជននៅមន្ទីរសន្តិសុខក្នុងស្រុកថ្មពួកនេះ លោកក៏បានដឹងខ្លះៗដែរពីសកម្មភាពរបស់ពួកវា ។ ដំណាក់កាលទី១របស់ពួកខ្មែរក្រហមគឺចាប់ពួកប៉ូលីស ទាហ៊ាន ឬអ្នកជាប់និន្នាការ កាលពីសម័យលន់ណុល ឬក៏ពួកនិស្សិត ពួកអ្នកមានសក្តិភូមិ នាយទុន យកទៅដាក់ក្នុងមន្ទីរសន្តិសុខ ចំពោះអ្នកដែល ជាប់ក្នុងមន្ទីរនេះទាំងប៉ុន្មាន គឺសំលាប់ចោលទាំងអស់ អ្នកទាំងនោះគ្មានភ័ព្វសំណាងអាចរួចខ្លួនបានទេ។ ដំណាក់កាលទី២ គឺពួកខ្មែរក្រហមបានចាប់យកប្រជាជនមូលដ្ឋាន ទៅដាក់មន្ទីរសន្តិសុខនេះដែរ ដោយសារគ្រាន់តែមានកំហុសបន្តិចបន្តួច ដូចជាដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយទៀត ឬក៏មានរបបលើស ដោយមានត្រី ឬក្តាមខ្យង លើសអ្នកដទៃបន្តិច ក៏ពួកខ្មែរក្រហមចោទថាខ្មាំង ហើយចាប់ដាក់មន្ទីរសន្តិសុខ យកទៅសំលាប់ចោល។ មានប្រជាជនខ្លះ គ្រាន់តែមានកំហុសខាងភ្នួររាស់ដោយដើរខុសគន្លងនង្គ័លតាមបទបញ្ជារបស់ពួកវា ដូចជា ឱ្យដើរខាងស្តាំ ហើយដើរខាងឆ្វេង គឺចោទថាខ្មាំង ហើយចាប់សំលាប់ភ្លាម នៅចំពោះមុខអ្នកភ្ជួរទាំងអស់ ដើម្បីកុំអោយយកគំរូតាម ដោយមិនបាច់ដាក់មន្ទីរសន្តិសុខទេ ។ ដំណាក់កាលទី ៣

គឺប្រើល្បិចកលថា ជន្លៀសប្រជាជនមូលដ្ឋានចេញ គឺអោយទៅដាំ ក្រចៅ កប្បាស អោយមានកន្លែងហូបគ្រប់គ្រាន់ គឺអោយ រៀបចំឥវ៉ាន និងចំណីអាហារ ត្រៀមតាមផ្លូវ បងប្អូនប្រជាជនទាំងនោះត្រេកអរណាស់ គេរៀបចំជញ្ជូនឥវ៉ាន់ នាំកូនចៅទាំងគ្រួសារធ្វើដំណើរទៅតាមបទបញ្ជារបស់ពួកខ្មែរក្រហម គឺយកប្រជាជនតាមសាខានិមួយៗ មាន ៥ ទៅ ១០គ្រួសារ តាមពិតពួកខ្មែរក្រហមប្រើល្បិចយកប្រជាជនទាំងនោះទៅសំលាប់ចោល ។ រំលងបាន ៥ថ្ងៃ ទៅ មួយអាទិត្យ ទើបដឹងថា ប្រជាជនជន្លៀសទៅដាំក្រចៅ កប្បាស យកទៅសំលាប់នៅបន្ទាយទាហ៊ានថ្មពួក និងនៅអណ្តូង ជិតមន្ទីរសន្តិសុខ ។ បន្ទាយទាហ៊ានដែលពួកខ្មែរក្រហមយកទៅសំលាប់នេះ សព្វថ្ងៃស្ថិតនៅទី តាំងកងពលធំលេខ ៧ ប្រចាំស្រុកថ្មពួក ឯអណ្តូងនោះនៅជិតសាលាវិទ្យាល័យស្រុកថ្មពួកសព្វថ្ងៃនេះ ។

ក្រោយពីការយកប្រជាជនទៅសំលាប់ ពួកខ្មែរក្រហមបានបំបិទសិទ្ធសេរីភាពគ្រប់បែបយ៉ាង សូម្បីតែប្រជាជន ឬបងប្អូនយុវជន យុវនារី គ្រាន់តែនិយាយលេងសើចបន្តិចបន្តួច ពួកខ្មែរក្រហមចោទថាខុសសីលធម៌ ចាប់យកទៅ សំលាប់នៅចំពោះមុខមហាជនតែម្តង ។

ចំពោះការសំលាប់វិញ ពួកខ្មែរក្រហមយកប្រជាជនដែលជាប់ចោទនៅមន្ទីរសន្តិសុខ ទៅទំលាក់អណ្តូងមួយដែលមានជំរៅ ១០ ម ទំហំ ៨ ម បួនជ្រុង សព្វថ្ងៃនេះអណ្តូងនេះស្ថិតនៅភូមិពភ្លាក់ ឃុំគួរស្រុកថ្មពួក ។

ក្នុងឆ្នាំ ១៩៧៥ - ១៩៧៧ ទំនាក់ទំនងស្ថាប័ននៅស្រុកនេះ គឺពួកពាយព្យជាអ្នកគ្រប់គ្រង គឺមានការហូបចុកធម្មតា គឺរបប បបរឈ្នោល តែឆ្អែត ឯទិន្នផលដែលបានមកពីការបង្កបង្កើនផលបានច្រើន តែពួកខ្មែរក្រហមបានអប់រំថា អោយប្រជាជនអត់ទ្រាំខ្លះទៅ ព្រោះភោគផលដែលបងប្អូនធ្វើបានទាំងប៉ុន្មាន គឺយកទៅជួយអ្នកនៅតាមដងទន្លេ ព្រោះប្រជាជនរស់នៅទីនោះជិតដាច់ខ្យល់ស្លាប់ហើយ ដោយគ្មានស្រែធ្វើ ។ នៅដើមឆ្នាំ ១៩៧៧ ពួកនិរតីចូលមក ហើយចោទថា ពួកពាយព្យក្បត់ ក៏ចាប់គណៈស្រុកឈ្មោះ **ឆាត** យកទៅសំលាប់ចោល ឯគណៈស្រុកថ្មីឈ្មោះ **រាម** ពួកនិរតីបានប្រើនយោបាយមួយ គឺហៅកម្មាភិបាលតូចធំរបស់ពាយព្យប្រជុំ ឯអ្នកតូចតាចជន្លៀសចេញ តែធាតុពិតចាប់យកទៅសំលាប់ចោលទាំងអស់ ។

ក្នុងឆ្នាំ ១៩៧៧ ដដែល ពួកនិរតី បានកំចាត់ពួកកម្មាភិបាលពាយព្យចេញអស់ ហើយចាប់ផ្តើមគ្រប់គ្រងបន្តពីពួកពាយព្យមានការតឹងតែងខ្លាំងណាស់ គឺពួកនិរតីចាប់ផ្តើមសំលាប់ប្រជាជនមូលដ្ឋានម្តង ។ ហើយប្រជាជន ១៧មេសា រាងធូរបន្តិច ។ តែការហូបចុករិតត្បិតមែនទែន សូម្បីតែដើរពីផ្ទះមួយទៅផ្ទះមួយក៏មិនបានដែរ បើពួកវាឃើញ គឺចោទថាខ្នាំង ហើយចាប់សំលាប់ចោលភ្លាម ។ លោក **សខាត** បានបន្ថែម

ថា រូបលោកពេលនោះ កើតជំងឺហើម ពុំដែលស្គាល់ជាតិបាយអង្ករទេ គឺស្គាល់តែមើមក្ដួច ឬ ដំឡូង បន្តិចបន្តួចប៉ុណ្ណោះ ពេលនោះក៏យកអង្កាមមកបុកអោយម៉ត់ រួចលីងហូបជំនួសបាយ ។ នៅថ្ងៃមួយពេលឡើងភ្នំបានឃើញ បាយជ្រូករបស់ពួកនិរតីស្ទើរតែដាច់ចិត្តលួកយកមកហូប ព្រោះឃ្លានស្ទើរដាច់ខ្យល់ស្លាប់ទៅហើយ ប៉ុន្តែពុំហ៊ានទេ បើកាលណាធ្វើបែបនេះ រូបលោកពិតស្លាប់ពុំខានឡើយ បើពួកខ្មែរក្រហមឃើញលោកលួចបាយជ្រូកហូប ។ លោកពូខំអត់ទ្រាំដើរចេញទាំងស្រក់ទឹកភ្នែក ។

ឯបបរអង្ករ ៣ ឬ ៤ ស្លាបព្រា មានគ្នាដល់ទៅ ១០ នាក់ មូលហេតុនេះហើយ ទើបមានប្រជាជនច្រើនដែលត្រូវស្លាប់ដោយសារដាច់ពោះ ។ ចំពោះមេសហករណ៍គុំរូ ដែលលោក **សខ្វាត** រស់នៅនោះឈ្មោះ **អាគក** ។ **អាគក** នេះសាហាវណាស់ គ្មានអ្នកណាហ៊ានមើលមុខវាទេ បើហ៊ាន សំលឹងមុខហើយ វាឃើញពិតជាចាប់ចងស្លាបសេក ហើយសំលាប់ចោលមួយរំពេច ។

នៅដើមឆ្នាំ ១៩៧៩ គឺខែមករា ឪពុកម្ដាយ និងបងប្អូនរបស់លោក **ឯក សខ្វាត** ចំនួន ៧នាក់ត្រូវពួកខ្មែរក្រហមយកទៅសំលាប់ខ្លះ និងខ្លះទៀតស្លាប់ដោយដាច់ពោះ នៅក្នុងឆ្នាំ ១៩៧៨ ពេលដែលពួកនិរតីកាន់កាប់ មានជនរង គ្រោះម្នាក់បានរត់រួចពីមន្ទីរសន្តិសុខ ដោយពួកខ្មែរក្រហមយកគាត់ទៅសំលាប់ដោយកាប់ចំកញ្ចឹងករ ពេលនោះគាត់ធ្វើពុតជាស្លាប់ ពេលពួកខ្មែរក្រហមចេញអស់គាត់ក៏រត់ចេញពីមន្ទីរកន្លែងសំលាប់ ហើយក៏រួចខ្លួនរហូតដល់សព្វថ្ងៃនេះ ។ ជនរងគ្រោះនោះ ឈ្មោះ **ស៊ឹម សៀវ** សព្វថ្ងៃនៅភូមិពង្រ ឃុំម្កាក់ ស្រុកសេរីសោភ័ណ បើចង់រកសាក្សី ជនរងគ្រោះនេះ ទាល់តែសួរប្អូនជនរងគ្រោះ ឈ្មោះ **ស៊ឹម គយ** សព្វថ្ងៃនៅឃុំថ្មពួកនេះ ។

លោក **សខ្វាត** ក៏បានបញ្ជាក់ប្រាប់ពីភស្តុតាងមួយចំនួនដូចជា អដ្ឋិធាតុ ដែលគាស់បានពីរណ្ដៅអណ្ដូង និងបន្ទាយទាហ៊ាន ថា យកទៅតំកល់នៅ **វត្តពោធិវាល** ដែលបានធ្វើខ្ទមមួយប្រក់ស្បូវ មានទំហំ ២ ម៉ែត្រ បួនជ្រុង កាលពីឆ្នាំ ១៩៨២ ។ អដ្ឋិធាតុនោះមានប្រហែល ៧០០ គឺគាស់នៅបន្ទាយ ទាហ៊ានចំនួនប្រហែល ៤០០ និងនៅអណ្ដូងចំនួន ៣០០ អដ្ឋិធាតុ ។ ប៉ុន្តែភស្តុតាងទាំងនេះត្រូវរលប់រលាយអស់ហើយដោយនៅឆ្នាំ ១៩៨៥ ពួកខ្មែរក្រហមវាយចូលស្រុកថ្មពួកនេះ ហើយពួកវាបានដុតបំផ្លាញផ្ទះសំបែងប្រជជន ដុតអដ្ឋិធាតុនៅវត្តពោធិវាល និងបាញ់សំលាប់ប្រជាជនអស់ជាច្រើននាក់ ។ ឯរូបលោកវិញក៏ត្រូវពួកខ្មែរក្រហមដេញបាញ់សំលាប់ដោយគ្រាប់បែ (B40)ធំៗ តែភព្វសំណាងល្អ គ្រាប់ទាំងប៉ុន្មានពុំបានត្រូវសាច់លោកទេ គឺគ្រាន់តែឆេះ ខោអាវ និងខ្លួនប៉ុណ្ណោះ ។

នៅក្នុងស្រុកថ្មពួកនេះ មានមនុស្សច្រើនណាស់ត្រូវបានពួកខ្មែរក្រហមសំលាប់ ប៉ុន្តែយើងមិនដឹងកន្លែងពួកវាសំលាប់ទេ គឺដឹងតែ ២ ឬ ៣ កន្លែងប៉ុណ្ណោះ ។

លោក **សខ្វាត** ក៏បានបន្ថែមថាការគាស់អដ្ឋិធាតុ គឺរូបលោកផ្ទាល់តែម្តងជាអ្នកចូលរួមដោយផ្ទាល់ដៃនៅក្នុងឆ្នាំ ១៩៨២ ។ រូបលោកជាសមាជិកគណៈកម្មាធិការឃុំថ្មពួក ទទួលបន្ទុកខាងសង្គមកិច្ច និងវប្បធម៌ ។ ពេលគាស់អដ្ឋិធាតុនេះសោត គឺលោកឃើញកន្សែងរុំមុខ និងចំណងចងជាប់នៅដៃជនរងគ្រោះនៅឡើយ គឺពុំទាន់រលួយទេ ។ ទីតាំងរណ្តៅមាន ៣ កន្លែង គឺអណ្តូងមួយគេហៅថាអណ្តូង **សែបផេង** ដែលមានទីតាំងនៅភូមិពភ្លាក់ ឃុំគុំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មានជំរៅ ១០ ម៉ែត្រ ទំហំ ៨ម៉ែត្របួនជ្រុង ដែលមានចំងាយ ប្រហែល ១.៥ គីឡូម៉ែត្រ ពីសាលាស្រុកថ្មពួក ។ ទី២ នៅបន្ទាយទាហ៊ានគឺស្ថិតនៅខាងជើងសាលាស្រុក ចំងាយ ៧០០ ម៉ែត្រ ដែលសព្វថ្ងៃហៅថា កងពលធំលេខ ៧ ប្រចាំស្រុកថ្មពួកមានចំនួន ៤ រណ្តៅ ។ រណ្តៅនីមួយៗ មានទំហំ ៨ ម៉ែត្រ ទទឹង ៣ ម៉ែត្រ ជំរៅ ២ ម៉ែត្រ ក្នុង ៤ នោះគាស់បានតែមួយរណ្តៅទេ ។ ទី ៣ គឺស្ថិតនៅភូមិដៃកកេះ ឃុំបន្ទាយឆ្មា ស្រុកថ្មពួក មានចំនួន ២ រណ្តៅទីតាំងរណ្តៅនោះហៅថា **ត្រពាំងស្នួល**។ តាមពិត រណ្តៅ២នេះ ជារណ្តៅដែលប្រជាជនគាស់រកមាសទេតែគាស់ទៅប៉ះចំរណ្តៅសាកសព ដែលពួកខ្មែរក្រហមសំលាប់ ។ ពួកអ្នកស្រុកគ្មានបំណងគាស់អដ្ឋិធាតុទេហើយកន្លែង រណ្តៅទាំងពីរនេះ រូបលោកពុំស្គាល់ទេ គឺពឹងអោយលោក **គី គាថ** មានឋានៈជាអនុសេនីឯកមេបញ្ជាការ ខាងវិស្វកម្ម $F_7$ ជាអ្នកជូនទៅ ។ ភស្តុតាងនៅទីនេះ បន្សល់ទុក ឆ្អឹងតូចៗ និងក្រណាត់ខោអាវខ្លះៗជាសំគាល់ ។

លោក **សខ្វាត** ក៏បានសន្និដ្ឋានថា មានរណ្តៅសំលាប់ច្រើនណាស់ដែលរូបលោកពុំដឹង តួយ៉ាងដូចរណ្តៅ ២ នេះ ជាដើម ព្រោះសម័យប៉ុលពត ពួកខ្មែរក្រហមយកប្រជាជនទៅសំលាប់សុទ្ធតែលក្ខការណ៍ពុំអោយ ប្រជាជនដឹងទេ ហេតុដូច្នេះហើយទើបរូបលោកមានការពិបាកក្នុងការស្វែងរករណ្តៅទាំងនោះ ។

នៅទីបញ្ចប់លោកបានបន្ថែមថា រូបលោកអាចរស់រានមានជីវិតបាន អាស្រ័យដោយគាត់ខិតខំធ្វើការទោះបីមានជំងឺហើមយ៉ាងណាក៏ដោយ ក៏លោកនៅតែទ្រាំអត់ធ្មត់ដើម្បីជីវិតរស់ ។ ពេលពួកខ្មែរក្រហមប្រមូលផ្តុំប្រជាជនម្តងៗ រូបលោកបានគេចចេញពីកន្លែងមួយទៅកន្លែងមួយទៀត គឺលាក់ខ្លួនតាមកងចល័តតែក៏ដោយសា នៅចុងឆ្នាំ ១៩៧៨ ច្បាប់របស់ពួកខ្មែរក្រហមរាងធូរស្រាលជាងមុនបន្តិច ឯឪពុកម្តាយនិងបងប្អូនរបស់លោករស់នៅកន្លែងប្រមូលផ្តុំត្រូវស្លាប់បាត់បង់ជីវិតអស់ហើយ ។ លោក **សខ្វាត** បានមាន

ប្រសាសន៍ថា ពួកប៉ុលពតនេះសាហាវឃោរឃៅណាស់ រូបលោកពុំ អាចបំភ្លេចនូវគំនុំអតីតកាលនេះបានទេ ចំពោះអំពើររបស់ ពួកវាមកលើរូបលោក ។

បន្ទាប់ពីបញ្ចប់ការសម្ភាសន៍ជាមួយលោក **ឯក សខ្វាត** ក្រុមយើងក៏ចាប់សំភាសន៍បន្តជាមួយ លោកអ៊ុំ **ហាប់ ស្វាង** មានអាយុ ៦៩ ឆ្នាំ ស្រុកកំណើតនៅភូមិ វត្តចាស់ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបាត់ដំបង ។ ក្នុងសម័យប៉ុលពត លោកអ៊ុំរស់នៅ ស្រុកកំណើតដដែល គឺភូមិឯកភាព ឃុំគុំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ សព្វថ្ងៃ អ៊ុំ **ស្វាង** មានតួនាទីជាសង្គមកិច្ចនិងវប្បធម៌ ប្រចាំនៅស្រុកថ្មពួក ។ ក្នុងរបបប៉ុលពត អ៊ុំ **ស្វាង** ជាគ្រូសង្គមកិច្ចនៅស្រុកថ្មពួក ជាអ្នកមើលជំងឺអោយប្រជាជន នៅក្នុងស្រុកនេះ ដូចជាជំងឺហើម រាគរូស គ្រុនក្តៅ ជាដើម ឯថ្នាំនេះទៀតសោត អ៊ុំរកបានមកពីការកាប់ឬសឈើ ឬសព្រៃធ្វើ តាមបែបបុរាណ គឺធ្វើដោយខ្លួនឯង ។ ក្រោយមកមានចិនម្នាក់ឈ្មោះ **ទៀន** ប្រពន្ធឈ្មោះ **លន់** គាត់នេះ ជំនាញខាងការវះកាត់ណាស់ តាំងពីសម័យលន់ណុលម្ល៉េះ គាត់បានបង្រៀនអោយលោក អ៊ុំ **ស្វាង** ចេះស្លថ្នាំ អំពូល ដោយយកឬសឈើទាំងនោះស្លផ្សំគ្នាដើម្បីធ្វើជាថ្នាំទឹក ។ ក្នុងការស្លថ្នាំនេះ ក៏មានយុវជន ៤នាក់ទៀត បានចូលរួមសហការណ៍គ្នាដែរ ។ ក្រោយមក ពេលពួកនិរតីមកកាន់កាប់ គ្រូពេទ្យឈ្មោះ **ទៀន** និងប្រពន្ធ ត្រូវពួកខ្មែរក្រហមចាប់ យកទាំងពីរនាក់ទៅសំលាប់ចោល ។ ឯរូបលោកអ៊ុំត្រូវប្រចាំការនៅក្នុងមន្ទីរពេទ្យនេះ មានឋានៈជាអ្នកមើលជំងឺ ផ្នែកហើម រាគរូស ក្តៅ ឬ ស្រ្តីរាំងរដូវ ដដែល ។ នៅពេលពួកនិរតីចូលមកកាន់កាប់ តំបន់នេះស៊ប់មែនទែន ពួកខ្មែរក្រហមអោយលោកអ៊ុំទៅកាប់ចំការវិញ ហើយពួកវាយកនារីនិរតីម្នាក់មក អោយមើលការខុសត្រូវក្នុងមន្ទីរពេទ្យស្រុកថ្មពួក ជំនួសលោកអ៊ុំវិញ ។ ចំពោះអ្នកជំងឺដែលចូលមកព្យាបាល នៅមន្ទីរពេទ្យនេះ ភាគច្រើនត្រូវស្លាប់ ភាគតិចណាស់ដែលមានវាសនានៅរស់ ព្រោះពេទ្យនេះប្រើតែថ្នាំឬស ឈើ ឬសព្រៃតាមបែបបុរាណខ្មែរប៉ុណ្ណោះ ។ ចំពោះការសំលាប់វិញ គឺពួកខ្មែរក្រហមប្រើកលល្បិចថាជន្លៀស ប្រជាជនអោយចេញទៅដាំ កប្បាស ក្រចៅ តាមពិតពួកវាចាប់ ទាំងគ្រួសារៗ យកមកដាក់បញ្ចូលក្នុងរោង មួយដ៏ធំបិទជិតឈឹង ។ រោងនេះពួកខ្មែរក្រហមហៅសាលា មហោស្រព សាលានេះអាចដាក់ប្រជាជនចំនួន ៥ ពាន់នាក់ ។ ឯ គោ ក្របី រទេះ របស់ប្រជាជន យកទៅដាក់ សហករណ៍ផ្សេងទៀត ពេលយប់ពួកខ្មែរក្រហម ប្រើល្បិចយកឡានបើកចុះបើកឡើង ថាដឹកប្រជាជនដែល ត្រូវជន្លៀសចេញ ។ ការពិតគ្មានដឹកទេ ។ ប្រជាជនទាំងនោះ ត្រូវចាប់យកទៅសំលាប់នៅបន្ទាយទាហ៊ាន សព្វថ្ងៃស្ថិតនៅកន្លែងកងពលធំលេខ ៧ប្រចាំ ស្រុកថ្មពួក និងកន្លែងឯទៀត គឺ **អណ្តូងស៊ែបផេង** ដូចលោក **សខ្វាត** រៀបរាប់ខាងលើ ។ ចំពោះអណ្តូង នេះ ពេលពួកខ្មែរក្រហមយកប្រជាជនទៅសំលាប់ម្តងៗ បានយកស្លឹកដូងគ្របពីលើមួយជាន់ ។ ពេលសំលាប់

លើកក្រោយគ្រប់មួយជាន់ៗទៀត ។ ការគ្រប់ស្លឹកដូង នេះមានប្រហែល ៧ ជាន់ អ៊ុំអាចដឹងបានដោយសារអ៊ុំក៏ជាអ្នកគាស់អដ្ឋិធាតុ ជាមួយលោក **ឯក សខ្វាត** កាលពីឆ្នាំ ១៩៨២ ។ លោកអ៊ុំបានបន្ថែមថា ពួកអាប៉ុលពតវាមានគំរោងមួយ គឺសំលាប់ប្រជាជនអោយអស់នៅ ឆ្នាំ ១៩៧៩ គឺក្រោយរដូវច្រូតកាត់រួច ។ ពេលសំលាប់នោះ ពួកខ្មែរក្រហមបំរុងធ្វើនំបញ្ចុកអោយហូប តែដោយសំណាងល្អ កងទ័ពវៀតណាមមកជួយរំដោះប្រជាជនយើងទាន់ពេលវេលា ។

លោកអ៊ុំបានបន្តទៀតថា លោកអ៊ុំរិះតែស្លាប់ទៅហើយនៅក្នុងរបបវានោះ គឺគណៈស្រុកថ្មពួកនេះបានយកលោកអ៊ុំទៅមើលកូនស្រីដែលកើតជំងឺឆ្កួត ។ ពេលនោះអ៊ុំភ័យណាស់ ព្រោះលោកអ៊ុំមិនដែលមើលជំងឺរបៀបនេះទេ ប៉ុន្តែអ៊ុំចេះតែ អោយថ្នាំឬសឈើ ឬសព្រៃ ដែលអ៊ុំផ្សំបានអោយកូនស្រីគណៈស្រុកនោះផឹកស្រាប់តែឈប់ឆ្កួត ហើយជា ធម្មតាវិញ ។ លោកអ៊ុំក៏រួចខ្លួនពីសេចក្ដីស្លាប់ ។ លើកទី២ គណៈស្រុកដដែលក៏បានហៅអោយលោកអ៊ុំទៅ មើលកូនស្រីម្នាក់ទៀតដែលគ្រុនក្ដៅ ពេលនោះលោកអ៊ុំរិតតែភ័យតក់ស្លុតថាម្ដងនេះពិតជាស្លាប់ហើយ តែសំណាង ល្អ លោកអ៊ុំចេះស្ដោះ ផ្លុំ បែបអបិយជំនឿ ស្រាប់កូនស្រីនោះជា ។ អ៊ុំក៏រួចខ្លួនម្ដងទៀត ។

លោកអ៊ុំបានបញ្ជាក់ប្រាប់អំពីទីតាំងរណ្ដៅដែលពួកខ្មែរក្រហមសំលាប់ប្រជាជន ។ ទីតាំងសំលាប់មានគ្រប់ឃុំ ដូចជា **ឃុំបន្ទាយឆ្មារ** មានប្រហែល ១០ រណ្ដៅ ក្នុងមួយរណ្ដៅៗមាន ៤ ម៉ែត្រ បួនជ្រុង ។ ហើយនៅស្រុកថ្មពួកនេះ គឺមួយឃុំបង្កើតសហករណ៍មួយ ឯទីតាំងសំលាប់គ្រប់សហករណ៍ក្នុងអំឡុងឆ្នាំ ១៩៧៧-១៩៧៨ ។

សរុបមក បើតាមកំណត់ហេតុរបស់លោក **ឯក សខ្វាត** និងលោកអ៊ុំ **ស្វាង** កាលពីឆ្នាំ ១៩៨៤ លោកទាំងពីរបាននិយាយថា ស្ថិតិដែលពួកខ្មែរក្រហមបានសំលាប់ប្រជាជននៅតាមឃុំនីមួយៗ គឺមានប្រហែលជា ៨ ពាន់ នាក់ ។ ឯអដ្ឋិធាតុ គាស់បានប្រហែល ៧០០ ប៉ុណ្ណោះ ។ ចំណែកឯកសារ និងភស្តុតាងនានាដូចជា អដ្ឋិធាតុ ត្រូវដុតចោល ដោយខ្មែរក្រហមបានវាយចូលស្រុកថ្មពួកនេះនៅឆ្នាំ ១៩៨៥ ។ ថ្ងៃទី ៣០-៩-១៩៨៥ ទាហ៊ានប៉ាវ៉ា បានវាយចូលក្នុងស្រុកថ្មពួកនេះម្ដងទៀត ឯភស្តុតាងនៅសេសសល់បន្តិចបន្តួចក៏ត្រូវបំផ្លាញម្ដងទៀត ។ ឯសាក្សីសំខាន់ម្នាក់ដែលនៅរស់ពីការឃុំខ្លួននៅមន្ទីរសន្តិសុខនោះ នៅឆ្ងាយពេក ហើយក្រុមយើងពុំអាចទៅបាន ។ជនរងគ្រោះក៏បានផ្លាស់ទីលំនៅពីស្រុកសិរីសោភ័ណពុំដឹងរស់នៅឯណាទេ គឺពុំស្គាល់អាស័យដ្ឋានច្បាស់លាស់ បើចង់ទៅរកសាក្សីនោះគឺត្រូវសួរបួនជនរងគ្រោះនោះសិន ទើបអាចរកឃើញ ។

ចុងក្រោយនៃកិច្ចសំភាសន៍ លោកអ៊ុំ **ហាប់ ស្វាង** និងលោក **ឯក សខ្ខាត** មានប្រសាសន៍ថា បើសិនជាមានតុលាការជាតិ ឬអង្គការអន្តរជាតិណាមួយបង្កើតតុលាការកាត់ទោសពួកប្រល័យពូជសាសន៍ ប៉ុលពត លោកទាំងពីរសុខចិត្តធ្វើសាក្សីដោយពុំខ្លាចញញើត គឺដើម្បីស្វែងរកយុត្តិធម៌អោយប្រជាជនកម្ពុជាយើង ដោយឥតរុញរា ព្រោះលោកទាំងពីរក៏មានបងប្អូនស្លាប់ និងទទួលទុក្ខវេទនាក្នុងរបប ៣ ឆ្នាំ ៨ខែនេះដែរ ។ លោកអ៊ុំ **ហាប់ ស្វាង** ត្រូវបាត់បង់បងប្អូនចំនួន ២គ្រួសារ សរុបស្លាប់អស់ ១០ នាក់ ឯលោក **ឯក សខ្ខាត** ត្រូវស្លាប់ទាំងឪពុកម្តាយ និងបងប្អូន ចំនួន ៧ នាក់ ដូច្នេះហើយ ទើបលោកទាំង ២ នៅតែមាន កំហឹងជានិច្ចចំពោះពួកខ្មែរក្រហម ។

នៅម៉ោង ៤:៣០នាទី ល្ងាច ថ្ងៃដដែល បន្ទាប់ពីចប់កិច្ចសំភាសន៍ជាមួយសាក្សី ក្រុមរបស់យើងបានបន្តដំណើរទៅពិនិត្យរណ្តៅសាកសព ជាកន្លែងដែលគាស់អដ្ឋិធាតុ មានចំនួន ៣កន្លែង ដែលយើងបានរៀបរាប់ឈ្មោះរួចហើយនៅទំព័រខាងលើ ។ ទីតាំងសំលាប់ ៣ កន្លែង នេះមានចំនួនរណ្តៅ ៧ រណ្តៅ ។ អ្នកជូនដំណើរក្រុមយើងទៅ រួមមាន លោក **ឯក សខ្ខាត** និងលោក **គីគាថ** ជាអនុសេនីឯកមេបញ្ជាការខាងវិស្វកម្ម $F_7$ ដែលសព្វថ្ងៃនៅ ភូមិឯកភាព ឃុំគុំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

បច្ចុប្បន្ន រណ្តៅទាំងអស់នេះស្ទើរតែរលប់ស្នាមអស់ទៅហើយ ប៉ុន្តែក្រុមស្រាវជ្រាវរបស់យើងបានថតរូបភាពរណ្តៅទាំងនេះទុកជាវត្ថុតាងដល់មនុស្សជំនាន់ក្រោយ និងទុកជាប្រវត្តិសាស្ត្រ ។

ក្រោយពីបានពិនិត្យរណ្តៅសាកសពរួច ក្រុមរបស់យើងក៏បានសម្រេចចិត្តទៅមើលប្រាសាទ **បន្ទាយឆ្មារ** ដែលស្ថិតនៅចំងាយ ១៦ គ.ម ពីទីរួមស្រុកថ្មពួក ដើម្បីចង់ដឹង និងឃើញនូវទិដ្ឋភាពប្រាសាទនេះអោយច្បាស់នឹងភ្នែក ថាតើហេតុអ្វីក៏មានកូនស្តេចស្រីថៃចុះមកទស្សនៈកិច្ចនៅប្រាសាទនេះ ។

នៅម៉ោង ៥:០០ ល្ងាច ថ្ងៃដដែល ក្រុមរបស់យើងបានទៅដល់ **ប្រាសាទបន្ទាយឆ្មារ** បើតាមការសាកសួរពីអ្នកស្រុករស់នៅតំបន់នេះ បានអោយដឹងថា នៅថ្ងៃទី ២២-៦-១៩៩៨នេះ មានកូនស្តេចថៃឈ្មោះ **ស៊ុរិនថន** អាយុ ៤៦ និងមានកូនសិស្សរបៀបជាទាហ៊ាន មកត្រួតពិនិត្យទីតាំងភូមិសាស្ត្រ ដោយដើរមើលជុំវិញប្រាសាទ និងក្នុងបរិវេណ ដោយចំណាយលុយអស់ ១០ម៉ឺនបាត សំរាប់ធ្វើផ្លូវដើរចូល **ប្រាសាទបន្ទាយឆ្មារ** និងធ្វើកូនខ្ទមតូចមួយសំរាប់ផ្លាស់សំលៀកបំពាក់ និង បង្គន់ សំរាប់ពេលទស្សនៈកិច្ចនេះ ។

បើតាមលោក **គីគាថ** និងកំលាំងកងរាជអាវុធហត្ថការពារសុវត្ថិភាពអភិបាលខេត្ត បានជជែកគ្នាថាពេលកូនស្តេចថៃនោះ ចុះពីលើយន្តហោះដើរមើលប្រាសាទមួយជុំ មានទឹកមុខមាំ ដោយគ្មាននិយាយស្តីឬថ្លែងសន្ទរកថាអរគុណ ចំពោះសម្តេចព្រះរាម **បុប្ផាទេវី** ក៏ដូចជាចៅហ្វាយខេត្ត ដែលខំជូនដំណើរទៅនោះ

សូម្បីតែមួយម៉ាត់ក៏គ្មានផង ។ រីឯក្រុមស្រាវជ្រាវយើងដែលបានអង្គុយហូបបាយក្បែរក្រុមកងរាជអាវុធហត្ថ នៅឯមន្ទីរគណបក្សប្រជាជនប្រចាំស្រុកថ្មពួក យល់ថា សកម្មភាពរបស់កូនស្ដេចថៃនេះ សរបញ្ជាក់អោយដឹងថា ការដែលពួកគេមកធ្វើទស្សនកិច្ចនេះ ពិតជាមានបំណងអ្វីមួយមិនខានឡើយ ។ បើតាមការដែលក្រុមរបស់យើងបានទៅដល់ **ប្រាសាទបន្ទាយឆ្មារ** ហើយបានឃើញផ្ទាល់ភ្នែក ពីទិដ្ឋភាពនៃប្រាសាទទាំងនោះ គឺគួរអោយរន្ធត់ចិត្តណាស់ ប្រាសាទទាំងអស់ត្រូវ បានបាក់បែកស្ទើរតែទាំងអស់ទៅហើយ ដុំថ្មធំៗគរជាគំនរត្រួតលើគ្នា សូម្បីតែផ្លូវដើរចូលទៅក្នុងប្រសាទក៏ពុំកើតផង ព្រោះថ្មបានបិទបាំងផ្លូវអស់ទៅហើយ ។

**ប្រាសាទបន្ទាយឆ្មារ** នេះមានទំហំ១គីឡូម៉ែត្រ បួនជ្រុង ត្រូវបាក់បែកខ្ទេចខ្ទីអស់ បន្សល់ទុកនៅតែដុំថ្មផ្ទាំងធំៗ មានគំនរដូចកូនភ្នំប៉ុណ្ណោះ ។ បើតាមលោក **គឹគាច** និងលោក **ឯក សខ្មាត** ដែលបានចូលរួមក្នុងដំណើរជាមួយក្រុមយើងនៅឯ **ប្រាសាទបន្ទាយឆ្មា** បានអោយដឹងថា ប្រាសាទទាំងនេះ កាលពីមុនត្រូវកាន់កាប់ដោយទ័ពរំដោះ គឺពួកសិរីការ ។ ឯគណៈបក្សប្រជាជនពុំបានកាន់កាប់ទេ ។ ក្នុងអំឡុងក្រោយបោះឆ្នោត ១៩៩៨ ទើបគណៈបក្សប្រជាជនបានចូលរួមសហការណ៍ជាមួយគណៈបក្ស **ហ៊្វុនស៊ិនប៉ិច** ការពារតំបន់នេះ ។ ឯគណៈបក្សប្រជាជនពុំបានចូលរួមចំណែកនៃការបែកបាក់ប្រាសាទនេះទេ ព្រោះអំឡុងពេលពួកទ័ពរំដោះកាន់កាប់ មេធំៗមួយចំនួនបានបញ្ជារអោយកូនចៅរបស់ខ្លួនកាប់គាស់រករូបក្បាលអ្នកតាពីខាងក្រោមប្រាសាទ ធ្វើអោយប្រាសាទទាំងនោះបាក់បែក ហើយធ្លាក់ថ្មចំកូនចៅរបស់ពួកគេស្លាប់អស់មួយចំនួនធំ ។

មុនឆ្នាំ ១៩៩០ ប្រាសាទនេះពុំទាន់បាក់បែកខ្លាំងក្លាទេ គឺបន្តិចបន្តួច ។ បន្ទាប់ពីពួកមេទាហ៊ានគាស់ឬសគល់នៃប្រាសាទដើម្បីស្វែងរករូបចំលាក់ក្បាលអ្នកតា ដើម្បីយកទៅលក់អោយប្រទេសថៃមកប្រាសាទនេះត្រូវបាក់បែកជាបំបែកៗមានតែគំនរថ្ម ឯផ្ទាំងថ្មនេះទៀតសោត ពួកថៃបានអោយតម្លៃ ១ផ្ទាំង ៣ ពាន់ទៅ ៤ ពាន់ បាត បើអ្នកណាយកទៅដល់ប្រទេសថៃ ។

បើតាមលោក **ឯក សខ្មាត** បាននិយាយថា ពួកថៃធ្វើរបៀបនេះក្នុងគោលបំណងបំផ្លិចបំផ្លាញវប្បធម៌ជាតិយើង ដោយយកប្រាក់មកទិញទឹកចិត្តខ្មែរយើងដូចសម័យលង្វែកអញ្ជឹង ។ លោកបានបន្ថែមថា កុំបន្ទោសអ្នកណាអោយសោះ នេះមកពីខ្មែរយើងមិនចេះគិត មិនចេះស្រលាញ់ជាតិឯង គិតតែពីផលប្រយោជន៍សួនតួរ ហើយបានប្រព្រឹត្តអំពើរបែបនេះមិនឈប់ឈរ គឺស៊ីមិនព្រមឆ្អែត ទាល់តែហេវ គឺរកកំលាំងធ្វើការអ្វីជាប្រយោជន៍ដល់សង្គមសឹងតែមិនបាន ។ លោកក៏ប្រាប់ពួកយើងអំពីព្រំប្រទល់ថៃថា ពួកថៃលួចដីយើងបន្តិចម្ដងៗ បើក្មួយចង់ទៅមើលព្រំដែននៅឯបឹងត្រកួន រូបគាត់ធានាជូនទៅ ព្រោះវាមានចំងាយជាង

២០ គ.ម ពីទីរួមស្រុកទេ បើក្តួយទៅដល់ ក្តួយ១ពិតជាស្រក់ទឹកភ្នែកមិនខានទេ ព្រោះស្តាយ ទឹកដីរបស់ខ្មែរ ដែលពួកថៃលួចបង្ខិតបង្គោលសីមា "ឬបង្គោលឡាក់" នោះអស់ជាច្រើនគីឡូម៉ែត្រ ពូមានការសោកស្តាយណាស់ តែពុំដឹងធ្វើម៉េចទេ ព្រោះគ្មានលទ្ធភាពជួយ បើពួកអ្នកធំ១មិនគិតផង ។ ទឹកមុខលោកពូនិយាយមើលទៅហាក់ដូចជាមានការសោកស្តាយ និងឈឺចាប់ណាស់នៅពេលគាត់ទៅឃើញដីខ្មែរ ក្លាយជារបស់ថៃទៅ វិញ ។ ឯនៅបឹងត្រកួនតាមព្រំដែន ពួកថៃក៏បានលួចដីខ្មែរបន្តិចម្តង១ដែរ លោកស្ទើរតែស្រក់ទឹកភ្នែកទៅ ហើយពេលឃើញទិដ្ឋភាពបែបនេះ ព្រោះលោកគ្មានសមត្ថភាពអាចជួយរួច ។ ត្រង់ចំណុចនេះ នាងខ្ញុំ (**ឯម សុឃឹម**) ក៏បានសួរទៅលោកពូវិញថា ចុះអាជ្ញាធរខេត្តមិនបានគិតគូពីបញ្ហានេះទេឬ ។ លោកមានប្រសាសន៍ " ពួកគេ មើលមិនឃើញទេ" ។ គាត់ក៏បញ្ចប់ប្រយោគត្រឹមនេះ ប្រហែលជាគាត់ខ្លាចនិយាយប៉ះពាល់ដល់មេ១ហើយ ទើបឈប់និយាយពីរឿងនេះ ។ បើយើងជាកូនខ្មែរ ក្រឡេកមើលប្រវត្តិសាស្ត្រនៃអតីតកាល ក៏បញ្ជាក់ឱ្យដឹងថា ប្រទេសជិតខាងតែងតែ ទន្ទ្រានចង់បានដីរបស់យើង រហូតមកដល់សព្វថ្ងៃ ។

បន្ទាប់ពីបានទស្សនាប្រាសាទ **បន្ទាយឆ្មារ** រួចមកក្រុមរបស់យើងក៏ត្រឡប់មកស្រុកថ្មពួកនៅម៉ោង ៦:០០ ល្ងាច ថ្ងៃដដែល ដើម្បីត្រៀមត្រលប់មកទីរួមខេត្តបន្ទាយមានជ័យវិញនៅថ្ងៃបន្ទាប់ ។

រួមសេចក្តីមក ការចុះស្រាវជ្រាវ និងសំភាសន៍សាក្សីនៅខេត្តបន្ទាយមានជ័យទទួលបានលទ្ធផលតិចតួច ដោយសារតែក្រុមរបស់យើងចុះទៅតែស្រុកថ្មពួកមួយប៉ុណ្ណោះ ឯស្រុកបន្ទាយអំពិលយើងពុំបានទៅទេ ដោយមូលហេតុស្រុកនេះនៅចំណុះខេត្តឧត្តរមានជ័យ បើចង់ទៅ ទាល់តែទៅទំនាក់ទំនងអាជ្ញាធរខេត្តជាមុនសិន ហើយម្យ៉ាងទៀត ផ្លូវទៅតាមស្រុកនេះមានការលំបាកជាខ្លាំង ផ្លូវគមនាគមន៍ ក្រហូងធំ១ ស្ពានត្រូវដាច់ដោយទឹកជំនន់ ពុំអាចធ្វើដំណើរដោយរថយន្តបានទេ គឺត្រូវឆ្លងក្បូន បន្ទាប់មកជិះរទេះគោបន្ត ឯចំងាយផ្លូវមានប្រវែង ៧០គីឡូម៉ែត្រ ប្រើរយៈពេលមួយថ្ងៃទើបអាចទៅដល់ ប៉ុន្តែបើរដូវប្រាំង បង្កលក្ខណៈងាយស្រួលជាង រដូវវស្សា ។

ចំពោះសាក្សីជនរងគ្រោះ ដែលជាប់នៅមន្ទីរសន្តិសុខផ្ទាល់ នៅឆ្ងាយពុំដឹងអាស័យដ្ឋានច្បាស់លាស់ ហើយពេលវេលាពុំអនុគ្រោះអោយក្រុមរបស់យើងទៅសំភាសន៍បាន ។ ប៉ុន្តែទោះបីជាទទួលបានលទ្ធផលតិចក៏ដោយ ក៏យើងអាចយកឯកសារទាំងនេះទៅចងក្រង និងបោះពុម្ពជាសៀវភៅ ទុកជាប្រវត្តិសាស្ត្រអោយមនុស្សជំនាន់ក្រោយជួយដឹងពីរបប **៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ** សំរាប់ប្រទេសកម្ពុជាយើងដែរ ។

កំណត់សំគាល់

— ទីតាំងទី១ មានចំងាយពីមន្ទីរស្រុកប្រហែល ៧០០ ម៉ែត្រ ចុះពីផ្លូវលេខ ៦៩អា ប្រហែល ១០ម៉ែត្រ

— ទីតាំងរណ្ដៅទី២ មានចំងាយប្រហែល ១៥០០ ម៉ែត្រ ពីមន្ទីរស្រុក ចុះពីផ្លូវលេខ ៦៩អា ប្រហែល ៥០ម៉ែត្រ គឺនៅក្រោយផ្ទះប្រជាជន ។

— ទីតាំងរណ្ដៅទី៣ មានចំងាយប្រហែល ៧៥០០ម៉ែត្រ ពីទីរួមស្រុក ចុះពីផ្លូវលេខ ៦៩អា ប្រហែល ២៥០ម៉ែត្រ តាមបន្ទាយទាហ៊ាន ទីតាំងនេះហៅ ត្រពាំងសួង ។

